**ឯកសារអប់រំ**

ភាគនៃបណ្ណាញវែបសាយនេះផ្តល់នូវពត៌មានអំពីអំពើហឹង្សា ដែលអាចជួយអ្នក ឬដើម្បីអ្នកអាចជួយអ្នកដទៃ ។

អ្នកអាចស្រាវជ្រាវបន្ថែមអំពីអំពើហឹង្សាក្នុងគ្រួសារគឺជាអ្វី អំពីប្រភេទជាច្រើននៃចរិយាមារយាទ ដែលនាំឲ្យមានអំពើហឹង្សា ក្នុងគ្រួសារ អំពីបញ្ហាអន្តោប្រវេសន៍មានឥទ្ធិពលអ្វីខ្លះដល់អ្នក និងច្បាប់ស្តីអំពីការជួញដូរមនុស្ស ។

**តើអំពើហឹង្សាក្នុងគ្រួសារគឺជាអ្វី?**

បើសិនជាអ្នកត្រូវបំពារបំពាន ខាងរាយកាយ ផ្លូវភេទ ផ្លូវចិត្ត ដោយនរណាម្នាក់ក្នុងគ្រួសារ ដោយមនុស្សដែលអ្នកមាន កូនជាមួយ ឬដោយមនុស្សដែលអ្នកដើរលេងជាមួយ ទាំងនេះហើយជាអំពើហឹង្សាក្នុងគ្រួសារ ។ អ្នកមានសិទ្ធិត្រូវបានការ ពារចំពោះមនុស្សដែលធ្វើបាបអ្នក ។

អំពើហឹង្សាក្នុងគ្រួសារគឺពេលមានមនុស្សណាម្នាក់ប៉ុនប៉ងត្រួតត្រាលើអ្នដទៃ ដោយប្រើអំពើបំភិតបំភ័យ គំរាមកំហែង បំពានផ្លូវភេទ ឃ្លាំមើល កាន់កាប់លុយកាក់ ឬគណនេយ្យ និងមានអាកប្បកិរិយាប្រហាក់ប្រហែលទាំងនោះ ។

អំពើហឹង្សាក្នុងគ្រួសារគឺជាគ្រោះថ្នាក់ ហើយតែងតែធ្ងន់ធ្ងរឡើង បើគ្មានគេជួយ ។
បញ្ជីខាងក្រោមនេះគឺជាឧទាហរណ៍អំពីចរិយាមារយាទ និងការបំពារបំពាន របស់ដៃគូរដែលជិតដិត អាចឈានទៅដល់ ដំណាក់ការគ្រោះថ្នាក់បន្ថែមទៀត ។

**<u>ហេតុការណ៍បន្តបន្ទាប់នៃអំពើហឹង្សា</u>**

| **<u>ផ្លូវចិត្ត</u>** : | **<u>ផ្លូវភេទ</u>** : |
|---|---|
| ● កំហោកឬជេរទ្រេចផ្តួនៗ | ● និយាយកំប្លែង និងបន្ថោកអំពីភេទ(ប្រុសស្រី) |
| ● កុហក់អំពីស្ថានភាពអន្តោប្រវេសន៍ | ● ប្រចាន់ (ឧទាហរណ៍ស្មានថាអ្នកមានប្រព្រឹត្តផ្លូវភេទ ជាមួយអ្នកដទៃ ។ |
| ● និយាយកុហក់ក្រុមគ្រួសារអ្នក អំពីអ្នក | ● ប៉ះពាល់ដោយគ្មានការយល់ព្រម |
| ● និយាយថាអ្នកបានបោះបង់វប្បធម៌របស់អ្នក ហើយក្លាយជា" ជនជាតិស្បែកស" ឬ"អាមេរិកាំង" | ● រិះគន់អំពីបញ្ហាផ្លូវភេទរបស់អ្នក |
| ● មិនអើពើ ឬបន្ថយសតិអារម្មណ៍របស់អ្នក | ● ហៅឈ្មោះដោយប្រើពាក្យទាក់ទិននិងផ្លូវភេទ |
| ● មិនផ្តល់ការយល់ព្រមឬការគាំទ្រផ្លូវចិត្ត ទុកជារបៀបពិន័យ | ● បង្ខំអ្នកឲ្យមើល ឬចូលរួមក្នុងរឿងអាសគ្រាម |
| ● បំភិតបំភ័យជាសាធារណៈ ឬជាឯកជន | ● បង្ខិតចង្ខំ ឬទាមទាររួមដំណេក (ប្រើការគំរាម) |
| ● ដាក់កំហុស ឬថ្កោលទោស | ● បង្ខំឲ្យរួមដំណេក ។ |
| ● ទាមទារការចាប់អារម្មណ៍ទាំងអស់របស់អ្នក | ● បង្ខំ ឬទាមទាររួមដំណេកក្រោយពេលមានផ្ទៃពោះឬវះកាត់ |
| ● គំរាមប្រឆាំងនឹងកូន ឬនឹងអាពាហ៍ពិពាហ៍ | ● រំលោភ |
| ● បន្ថយតួនាទីជាប្តីប្រពន្ធ ជាគូរស្នេហា ឬជាដៃគូរ | ● មិនឲ្យរួមដំណេក និងសេចក្តីស្រឡាញ់ |
| ● ប្រើជំនឿសាមញ្ញអំពីភេទ ឬតួនាទី | **<u>បំពារបំពានផ្នែកសេដ្ឋកិច្ច</u>** : |
| ● បន្ថោកវប្បធម៌ ឬសាសនារបស់អ្នក | ● បង្ខំអ្នកឲ្យធ្វើការដោយខុសច្បាប់ក្នុងពេលដែលអ្នកគ្មានប័ណ្ណ អនុញ្ញាតធ្វើការ |
| ● កាន់កាប់សេចក្តីសំរេចសំខាន់ៗ | ● គំរាមរាយការណ៍ទៅក្រសួងអន្តោប្រវេសន៍ បើសិនអ្នក ធ្វើការយកលុយខាងក្រៅ |
| ● អះអាងថាខ្លួនត្រួតត្រាបានជានិច្ច | ● មិនឲ្យអ្នកហ្វឹកហាត់ការងារ ឬរៀនសូត្រ |
| ● ថាអ្នកឆ្កួលជ្រើប ឈឺខួរក្បាល ឈឺផ្លូវចិត្ត មានអារម្មណ៍ ចង់សម្លាប់មនុស្ស | ● យកប្រាក់ដែលសំចៃទុកសំរាប់គ្រួសារអ្នកនៅឯស្រុក |

**ផ្លូវកាយ** :

- ប្រកែកមិនតម្រូវការចាំបាច់ខាងផ្លូវកាយរបស់មនុស្សក្នុងបន្ទុក
- ច្រាន ឬរុញ
- ធ្វើឲ្យស្ទះដង្ហើម ឬវាយដំ
- កន្ត្រាក់ ទះ ខាំ ឬក្តិច
- ចាប់អង្រួន ឬធ្វើឲ្យជាំ
- វាយ ដាល ទាត់
- បោកអ្នក
- ក្របួចអ្នក ហើយវាយ ឬដាល
- បង្អត់អាហារ ថ្នាំពេទ្យ និងដំណេក
- ដេÃ ឲ្យរហែក បាក់ឆ្អឹង និងរបួសក្នុងខ្លួន
- ប្រើអាវុធ ឬប្រើវត្ថុទាំងឡាយជាអាវុធ
- ធ្វើឲ្យពិការ ឬខូចខាតរាងកាយ
- ឃាដកម្ម

**ការបំភ័យ** :

- លាក់ឬបំផ្លាញឯកសារសំខាន់ៗ (លិខិតឆ្លងដែនរបស់អ្នក របស់កូនអ្នក ប័ណ្ណសំគាល់ខ្លួន គ្រីនកាត ។ល។
- បំផ្លាញរូបថតរបស់គ្រួសារអ្នក
- បំផ្លាញទ្រព្យសម្បត្តិដែលអ្នកយកមកពីប្រទេសរបស់អ្នក
- គំរាមកំហែងមនុស្សដែលគាំទ្រអ្នក គាំទ្រគ្រួសារនិងមិត្តភ័ក្រអ្នក
- គំរាមបញ្ចេញការសម្ងាត់របស់គ្រួសារ
- យករឿងអត្តឃាដជាការគំរាម
- ចំអកអំពីសញ្ជាតិ មុខរបរ ឬភេទ
- បំផ្លាញឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ
- បង្អួតកម្លាំង
- បង្ខំឲ្យចុះហត្ថលេខាលើឯកសារជាភាសាអង់គ្លេស ដែលអ្នកមិនយល់ (ឯកសារតុលាការ គំរូពីក្រសួងពន្ធដារ ឯកសារអន្តោប្រវេសន៍)

- មិនឲ្យអ្នកដឹងអំពីប្រាក់ចំណូលគ្រួសារ

**ផ្តាច់ការទាក់ទង** :

- ផ្តាច់ទំនាក់ទំនងរបស់អ្នកពីមិត្រភ័ក្រនិងគ្រួសារ
- មិនអនុញ្ញាតអ្នកឲ្យរៀនភាសាអង់គ្លេស
- មិនឲ្យអ្នកនិយាយគ្នា ប្រើភាសារបស់អ្នក
- អានសំបុត្ររបស់អ្នក ឬមិនអនុញ្ញាតឲ្យអ្នកប្រើទូរស័ព្ទ
- ផ្តាច់ការចុះឈ្មោះទិញ ឬបំផ្លាញកាសែត និងទស្សនាវដ្តីជាភាសារបស់អ្នក
- មិនអនុញ្ញាតឲ្យអ្នកជួបជាមួយមនុស្សដែលនិយាយភាសារបស់អ្នក មនុស្សពីសហគមន៍អ្នក ពីប្រទេសអ្នក ឬមានវប្បធម៌ដូចអ្នក
- បំបាត់ប្រព័ន្ធគាំទ្រ
- ធ្វើឲ្យអ្នកលែងជិតស្និទ្ធិជាមួយគ្រួសារឬមិត្តភ័ក្រ

**ប្រើក្មេង** :

- គំរាមរាយការណ៍កូនអ្នកទៅក្រសួងអន្តោប្រវេសន៍
- យកលុយរបស់អ្នកដែលគ្រោងផ្ញើទៅឧបត្ថម្ភកូននៅឯស្រុក
- គំរាមថាបញ្ជូនអ្នកទៅស្រុក ហើយទុកកូនអ្នកនៅសហរដ្ឋ
- ប្រាប់អ្នកថាបើអ្នកស្វែងរកការជួយពីតុលាការឬពីប៉ូលិសនោះ ប្រព័ន្ធច្បាប់នៅសហរដ្ឋនិងឲ្យជនបំពារបំពានយកកូនទៅថែរក្សា

## អន្តោប្រវេសន៍ និងអំពើហឹង្សាក្នុងគ្រួសារ

នៅក្នុងកាលៈទេសៈខ្លះ មានច្បាប់ពិសេសសំរាប់ការពារជនអន្តោប្រវេសន៍ដែលត្រូវរងនូវអំពើហឹង្សាក្នុងគ្រួសារ ឬ ការជួញដូរមនុស្ស។
កុំប៉ុន្តែចូរកុំទាក់ទងជាមួយក្រសួងអន្តោប្រវេសន៍ ដោយមិនទាន់បានទទួលឱវាទពីមេធាវី ឬពីអ្នកផ្តល់គំនិត ។
មានច្បាប់មួយដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកបានអនុម័ត មានឈ្មោះថា "ច្បាប់ស្តីអំពីហឹង្សាប្រឆាំងនឹងស្ត្រី" ។
ច្បាប់នេះផ្តល់ការការពារបន្ថែម ហើយជួយអ្នកឲ្យអាចត្រួតត្រាអនាគតរបស់ខ្លួន ។
ច្បាប់នេះបង្កើតបែបបទពីរយ៉ាង សំរាប់ស្ត្រីជាជនអន្តោប្រវេសន៍ដែលត្រូវគេបំពាន និងស្ត្រីដែលបានរៀបការជាមួយជនជាតិអាមេរិកាំង ឬជាមួយអ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ អាចទទួលការរស់នៅស្របច្បាប់បាន :

**I-360** ពាក្យសុំដោយខ្លួនឯង : គឺពុំបាច់ពឹងទៅលើប្តី ដើម្បីដាក់ពាក្យសុំសិទ្ធិរស់នៅ ទៅក្រសួងអន្តោប្រវេសន៍ **(USCIS)** ដែលពីមុនហៅថា INS នោះទេ តែអ្នកអាចដាក់ពាក្យសុំដោយខ្លួនឯងសំរាប់អ្នក និងសំរាប់កូនអ្នក។
ប្តីរបស់អ្នកគ្មានតួនាទីអ្វីក្នុងដំណើរការនោះទេ ហើយក៏មិនបាច់ដឹងថា អ្នកកំពុងដាក់ពាក្យសុំសិទ្ធិរស់នៅនោះទេ ។

**I-751** លុបចោលការបណ្តេញ : ច្បាប់នេះសំរាប់តែក្នុងករណីអ្នកកំពុងស្ថិតនៅក្នុងដំណើរការ ត្រូវបញ្ជូនវិលទៅប្រទេសដើមវិញ ។ បើអ្នកគ្រប់លក្ខណៈសំរាប់ការអនុវត្តន៍ "ច្បាប់លុបចោលការបញ្ជូន" នោះតុលាការអាចលើកលែងការបញ្ជូន ហើយផ្តល់ឲ្យអ្នកសិទ្ធិរស់នៅ ។ ទោះជាយ៉ាងនោះក៏ដោយ ពីព្រោះអ្នកកំពុងនៅក្នុងដំណើរការត្រូវបញ្ជូនទៅប្រទេសខ្លួនវិញ មុននឹងអ្នកដាក់ពាក្យសុំ អ្នកត្រូវជួបជាមួយមេធាវីអន្តោប្រវេសន៍សិន ។

ច្បាប់មានភាពស្មុគ្រស្មាញណាស់ ។ អ្នកមិនត្រូវទៅក្រសួងអន្តោប្រវេសន៍ ដោយមិនបានសួរយោបល់ពីអ្នកធ្វើការផ្នែកទីជំរក មេធាវីផ្នែកអន្តោប្រវេសន៍ ពីអង្គការបំរើកិច្ចការខាងអំពើហឹង្សាក្នុងគ្រួសារ ឬពីអង្គការធ្វើកិច្ចការផ្នែកអន្តោប្រវេសន៍នោះទេ ។
បើអ្នកយល់ថាអ្នកមិនគ្រប់លក្ខណៈតាមច្បាប់ស្តីអំពី "ហឹង្សាប្រឆាំងនឹងស្ត្រី" ទេនោះ អ្នកកុំអស់សង្ឃឹម ។
អាចមានផ្លូវផ្សេងទៀតដែលអ្នកទទួលបានលក្ខណៈជាអន្តោប្រវេសន៍ ដូចជាច្បាប់ "ទិដ្ឋាការថ្មី" ដែលរដ្ឋសភាបានបង្កើតឡើងសំរាប់ជនរងគ្រោះដោយអំពើឧក្រិដ្ឋ ។
ចូរអ្នកពិគ្រោះអំពីស្ថានភាពរបស់អ្នកជាមួយភ្នាក់ងារអន្តោប្រវេសន៍ ឬអ្នកផ្តល់គំនិតខាងអំពើហឹង្សាក្នុងគ្រួសារ ។

## ការជួញដូរមនុស្ស

ការជួញដូរមនុស្សជាបែបផែនមួយនៃការបំពារបំពាន ។ ការជួញដូរមនុស្សជាការបំពានសិទ្ធិមនុស្សក្នុងពិភពលោក នេះគឺបែបផែននៃទាសភាពសម័យទំនើប ។ ដើម្បីបានពត៏មានបន្ថែមអំពីបញ្ហាជួញដូរមនុស្សសូមអានឯកសារ :

- ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកអំពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម ។
- ក្រសួងមហាផ្ទៃសហរដ្ឋអាមេរិក ។